**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**ក្រសួងមហាផ្ទៃ**

លេខ: ៥៥០៨ ប្រក

# ប្រកាស
## ស្ដីពី
## ការបង្កើត និងដាក់ឱ្យប្រើប្រាស់នូវនិមិត្តសញ្ញាខេត្តសៀមរាប

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១៩/០០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦២២/០០៥ ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០២២ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្ដីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក
- យោងតាមសំណើរបស់រដ្ឋបាលខេត្តសៀមរាប

## សម្រេច

**ប្រការ១.-**

ត្រូវបានបង្កើត និងដាក់ឱ្យប្រើប្រាស់នូវនិមិត្តសញ្ញាខេត្តសៀមរាប ជាផ្លូវការដូចមាននៅក្នុងឧបសម្ព័ន្ធភ្ជាប់ជាមួយប្រកាសនេះ។

**ប្រការ២.-**

និមិត្តសញ្ញាខេត្តសៀមរាប មានរាង និងរូបភាពដែលត្រូវបានកំណត់ដូចខាងក្រោម៖

- មានរាងមូល
- **រូបប្រាសាទអង្គរវត្ត៖** ជាអត្តសញ្ញាណជាតិ ដែលបានចុះក្នុងបញ្ជីសម្បត្តិបេតិកភណ្ឌពិភពលោក នាថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៩២។ ប្រាសាទនេះត្រូវបានបុព្វបុរសខ្មែរកសាងនៅលើទឹកដីដ៏ពិសិដ្ឋ ដែលបានកសាងសេដ្ឋកិច្ច វប្បធម៌ ការពារទឹកដី ខឿននៃអរិយធម៌ ស្ថិតនៅចន្លោះភ្នំគូលែន និង បឹងទន្លេសាបក្នុងភូមិសាស្ត្រខេត្តសៀមរាប និងត្រូវបានទទួលស្គាល់ និងទម្លាប់ហៅតាមគ្នាថា "សៀមរាបអង្គរ"
- **រូបនាគ៖** តំណាងឱ្យពិភពចក្រវាលទាំងប្រាំពីរ គឺព្រះចន្ទ ព្រះអង្គារ ព្រះពុធ ព្រះព្រហស្បតិ៍ ព្រះសុក្រ ព្រះសៅរ៍ និងព្រះអាទិត្យ និងជានិមិត្តរូបនៃភាពត្រជាក់ត្រជុំ សុខដុមរមនា ការរួបរួមកម្លាំង សាមគ្គីភាព ក្រោមម្លប់នៃសុខសន្តិភាព តាមរយៈនយោបាយឈ្នះ-ឈ្នះ
- **រូបហោត់ទឹក៖** ជាឧបករណ៍ស្រោចស្រព តំណាងឱ្យប្រព័ន្ធធារាសាស្ត្រដែលមានតាំងពីសម័យ បុរាណកាល ហើយត្រូវបានអភិរក្ស និងអភិវឌ្ឍន៍រហូតដល់បច្ចុប្បន្ន ក្រោមនយោបាយទឹកសម្រាប់ ប្រើប្រាស់ក្នុងវិស័យកសិកម្ម និងជីវភាពរស់នៅរបស់ប្រជាជន
- **រូបទឹក និងត្រី៖** ក្រៅពីបឹងទន្លេសាប ត្រពាំង បឹង បួ អូរ ប្រឡាយធម្មជាតិ ក្រោមនយោបាយទឹក បារាយណ៍ទឹកថ្លា កសិណ ត្រូវបានរៀបចំសម្រាប់ជាប្រព័ន្ធការពារ សំណង់ស្ថាបត្យកម្ម និងគ្រឹះ នៃសេដ្ឋកិច្ចជាតិ ជាប្រភពនៃមច្ឆជាតិ និងជីវៈចម្រុះបម្រើដល់ប្រព័ន្ធស្បៀងអាហារ
- **កួរស្រូវ៖** តំណាងឱ្យវិស័យកសិកម្ម ដែលខេត្តសៀមរាបជាខេត្តមានសក្ដានុពលលើវិស័យកសិកម្ម តាំងពីបុរាណកាលមក ហើយវិស័យនេះនៅតែបន្តជ្រោងខឿនសេដ្ឋកិច្ចខេត្ត។ ក្រៅពីការផ្គត់ផ្គង់ ជីវភាពប្រជាជន ភាពសម្បូររុងរឿងនៃវិស័យកសិកម្មពេលបច្ចុប្បន្ននេះ បានជួយដោយប្រយោល លើវិស័យទេសចរណ៍ផងដែរ
- **ក្បាច់ផ្កាភ្ញីអង្គរ៖** តំណាងឱ្យខឿនវប្បធម៌នៃស្ថាបត្យកម្មរស់រវើករបស់ស្ថាបត្យករដ៏ល្អឯកក្នុងសម័យ បុរាណកាល
- **ខ្សែបូ៖** មានបីពណ៌យកតាមទង់ជាតិនៃព្រះរាជាណាចក្រកម្ពុជា សម្រាប់លើកតម្លៃ កិត្តិយស សោភ័ណភាព និងទ្រទ្រង់អត្ថន័យនៃនិមិត្តសញ្ញារបស់រដ្ឋបាលខេត្តសៀមរាប។

**ប្រការ៣.-**

និមិត្តសញ្ញាខេត្តសៀមរាប ត្រូវបានប្រើប្រាស់ជាផ្លូវការ ដូចខាងក្រោម៖

- ដាក់នៅកន្លែងធ្វើការងារ
- ដាក់នៅលើក្បាលលិខិត ឯកសារ និងស្រោមសំបុត្រផ្លូវការ
- ប្រើប្រាស់ក្នុងពិធីនានារបស់រដ្ឋបាលខេត្តសៀមរាប
- ប្រើប្រាស់ជាផ្លូវការក្នុងករណីផ្សេងៗទៀតដែលចាំបាច់។

**ប្រការ៤.-**

អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល អគ្គស្នងការនៃអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានភស្តុភារនិងហិរញ្ញវត្ថុ ប្រធានអង្គភាពផ្សេងទៀតចំណុះក្រសួងមហាផ្ទៃ ប្រធានក្រុមប្រឹក្សាខេត្តសៀមរាប និងអភិបាល នៃគណៈអភិបាលខេត្តសៀមរាប ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ...........ខែ...........ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី...០៥... ខែ...........ឆ្នាំ២០២៣

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**អភិសន្តិបណ្ឌិត ស សុខា**

**កន្លែងទទួល៖**

-ក្រសួងព្រះបរមរាជវាំង
-គ្រប់ក្រសួង ស្ថាប័ន
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចធិបតីនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
-រដ្ឋបាលរាជធានី ខេត្ត
-ដូចប្រការ៤
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធនៃប្រកាសលេខ...២៤០៨ ប្រក.....

ចុះថ្ងៃ.អង្គារ.........៨រោច... ខែ.......កត្តិក...........ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ត្រូវនឹងថ្ងៃទី.......០៥....... ខែ........ធ្នូ........ ឆ្នាំ ២០២៣

ស្តីពីការបង្កើត និងដាក់ឱ្យប្រើប្រាស់នូវនិមិត្តសញ្ញាខេត្តសៀមរាប




និមិត្តសញ្ញាខេត្តសៀមរាប